# ក្រសួងភាសាច្រើនយ៉ាង

ការិយាល័យបង្ហាត់បង្រៀនទិងរៀនសូត្រ

440 North Broad Street Suite 251
Philadelphia, PA 19130
(215) 400-4240

ជូនចំពោះមាតាបិតាឬអណាព្យាបាលរបស់ ____________________________________________________________,

យោងទៅតាមគោលបំណងអប់រំរបស់ក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា និងការធ្វើតាមការិយាល័យផ្នែកសិទ្ធិមនុស្ស ក្រសួងអប់រំរដ្ឋ ផិនស៊ីលវេនីញ៉ា Title 22, Chapter 4, Section 4.26 នៃបទបញ្ញាផ្នែកកម្មវិធីសិក្សា តម្រូវឲ្យក្រសួងអប់រំ ផ្តល់កម្មវិធីមួយ សម្រាប់សិស្សគ្រប់ៗរូប ដែលមិនសូវចេះភាសាអង់គ្លេស (LEP) ឬជាសិស្សដែលកំពុងរៀនភាសាអង់គ្លេស (ELL)។ បទបញ្ញាបានចែងថាៈ

ក្រសួងអប់រំនិមួយៗ ត្រូវផ្តល់កម្មវិធីមួយ សម្រាប់សិស្សម្នាក់ៗ ដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស ដើម្បីជួយសម្រួលសិស្ស ឲ្យមានការចេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ និងសម្រេចតាមខ្នាតនៃការសិក្សា ក្រោមជំពូក § 4.12 (ជាប់ទាក់ទងដល់ខ្នាតសិក្សា)។  កម្មវិធីផ្សេងៗក្រោមជំពូកនេះ ត្រូវមានរួម ការបង្ហាត់បង្រៀនជាភាសាឬវប្បធ៌មពីរយ៉ាង ឬអង់គ្លេសជាភាសាទីពីរ ឲ្យបានសមរម្យ។

ក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា បានបង្កើតកម្មវិធីសម្រាប់សិស្សនិយាយភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេស (ESOL) សម្រាប់សិស្ស ដែលកំពុងរៀនភាសាអង់គ្លេស។  គោលបំណងនៃកម្មវិធីនេះ គឺធ្វើឲ្យសិស្សមិនសូវចេះអង់គ្លេស ក្លាយទៅជាសិស្សមានសមត្ថភាព ក្នុងការ ស្តាប់ និយាយ អាន និងសរសេរ ភាសាអង់គ្លេស។

កំរិតភាសាអង់គ្លេសរបស់កូនលោកអ្នក ត្រូវបានស្ទង់មើលតាមការប្រើតែសចាត់តាំងរបស់រដ្ឋផិនសីលវេនីញ៉ា ហៅថា (WIDA-ACCESS Placement Test)។  ដោយបានពិន្ទុចំនួន ___________ កូនលោកអ្នក អាច និងទទួលឲ្យចុះឈ្មោះក្នុងកម្មវិធី ESOL។

យោងទៅតាមសេចក្តីតម្រូវរបស់រដ្ឋផិនស៊ីលវេនីញ៉ា សិស្សក្នុងកម្មវិធី ESOL នឹងទទួលការបង្ហាត់បង្រៀនពិសេស ផ្នែកភាសាអង់គ្លេស ហើយគ្រូ ESOL នឹងជួយសិស្ស រៀនមុខវិជ្ជាធម្មតាបានឆាប់រហ័ស។  កូនលោកអ្នក នឹងស្ថិតនៅក្នុងកម្មវិធី ESOL រហូតដល់សិស្សអាចចេញពីកម្មវិធីបាន (សូមអានទំព័រម្ខាងទៀត អំពីខ្នាតវិនិច្ឆ័យនៃការចេញពីកម្មវិធី)។

បើលោកអ្នកមានសំនួរអ្វីមួយ សូមទូរស័ព្ទមកខ្ញុំ តាមលេខ ______________________________ ។

ដោយសេចក្តីរាប់អាន

_________________________________________          ___________________________________
នាយកសាលា          សាលា

_________________________________________
គ្រូ ESOL

____________________________
ថ្ងៃខែ

## ខ្នាតវិនិច្ឆ័យសម្រាប់ការចេញពីកម្មវិធី ESOL

ខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញពីកម្មវិធីESOLតាមការតម្រូវរបស់រដ្ឋ ត្រូវមានបង្ហាញភស្តុតាងត្រឹមត្រូវ និងគួរឲ្យជឿបាន ថាសិស្ស ត្រូវចេះភាសាអង់គ្លេសគ្រប់គ្រាន់ មុននឹងសិស្សអាចចាកចេញពីកម្មវិធីបង្ហាត់បង្រៀនភាសាអង់គ្លេស។ ដើម្បីឲ្យត្រូវតាមខ្នាតវិនិច្ឆ័យ សម្រាប់ការចាកចេញកម្មវិធីសិក្សាELLតាមការតម្រូវរបស់រដ្ឋ សាលារៀន ត្រូវប្រើខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញ ពីរយ៉ាង ខាងក្រោមនេះ។ ជាបន្ថែម សាលាត្រូវបង្ហាញឲ្យច្បាស់ថា សិស្សត្រូវសម្រេចតាមខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញណាមួយ នៃ ខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញបន្ថែមពីរទៀត ដែលមានផ្តល់ខាងក្រោមនេះ ដើម្បីចាកចេញពីកម្មវិធីសិក្សាភាសាអង់គ្លេសៈ

<u>សេចក្តីតម្រូវនៃខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញ</u>

១. បានពិន្ទុ 5.0-Bridging ពីតែសនៃការស្ទង់ ពីការយល់ដឹង និងទំនាក់ទំនងពីក៏រិតមួយទៅក៏រិតមួយទៀត (Assessing Comprehension and Communication in English State-to-State - ACCESS)។ ការស្ទង់នេះ មានធ្វើឡើងជារៀងរាល់ឆ្នាំ ដល់សិស្សកំពុងរៀនអង់គ្លេស ដើម្បីចាត់ចែងនូវការចេះដឹងគ្រប់គ្រាន់របស់សិស្ស តាមខ្នាតចះដឹងគ្រប់គ្រាន់របស់រដ្ឋផិនស៊ីលវេនីញ៉ា ផ្នែកការ ស្តាប់ និយាយ អាន និង សរសេរ។ ពិន្ទុកម្រិត Bridging ត្រូវយកមកគិត ដោយបូករួមពិន្ទុពីការស្ទង់ទាំងអស់។

២. បានពិន្ទុ Basic ពីតែសនៃការស្ទង់សាលារបស់ប្រព័ន្ធរដ្ឋផិនស៊ីលវេនីញ៉ាប្រចាំឆ្នាំ - Pennsylvania System of School Assessment (PSSA)។

***កាលៈទេសៈពិសេសៗ:**

• សិស្សមកពីរដ្ឋផ្សេងទៀតៈ ប្រៀបធៀបលទ្ធផលនៃខ្នាតតែស ដើម្បីសម្រេចថាតើក៏រិតសិក្សា Proficiency នៃរដ្ឋនេះ មានក៏រិតស្មើ ជាមួយនឹង Basic នៃតែស PSSA ឬទេ។

• សិស្សរៀនទៅថ្នាក់ ដែលមិនត្រូវធ្វើតែស PSSA: ត្រូវធើឲ្យបានតាមខ្នាតវិនិច្ឆ័យនិមួយៗ នៃខ្នាតវិនិច្ឆ័យខាងក្រោម។

<u>ខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញបន្ថែមៈ</u>

១. ពិន្ទុចុងក្រោយបង្អស់ គឺបាន C ឬគ្រាន់បើជាង ពីមុខវិជ្ជាសំខាន់ៗ (ចំណោទ អក្សរសិល្ប៍ វិទ្យាសាស្ត្រ និង សង្គមសាស្ត្រ)

២. បានទទួលពិន្ទុ ពីតែសប្រចាំក្រសួង ដែលអាចប្រៀបធៀបទៅនឹងក៏រិត Basic នៃតែស PSSA។ (40%+ ពីតែស TerraNova ផ្នែកការអាន និងចំណោទ)

**កំណត់សំគាល់:** ក្រុម IEP អាចសម្រេចថា តើសិស្ស ELL ដែលត្រូវការការសិក្សាពិសេស គួរ ចេញពីកម្មវិ ESOL មុនរៀនបាន សម្រេច ទៅតាមខ្នាតវិនិច្ឆ័យសម្រាប់ការចាកចេញ ដោយយោងទៅតាមគោលបំណង IEP ផ្សេងៗ។

នៅពេលសិស្សបានចេញពីកម្មវិធី សំបុត្រជំរាបទៅមាតាបិតាសម្រាប់ឲ្យសិស្សចេញ (Parent Notification Letter for Student Exit) ត្រូវមានផ្ញើទៅមាតាបិតា/អណាព្យាបាល ដើម្បីជំរាបថា កូនរបស់គាត់ នឹងចេញពីកម្មវិធី ESOL។ ការចាកចេញពីកម្មវិធី អាចប្រព្រឹត្ត ទៅ នៅពេលកំពុងរៀនប្រចាំឆ្នាំសិក្សា។
**តាមការតម្រូវរបស់ច្បាប់ Title III សិស្សចេញពីកម្មវិធីទាំងអស់ ត្រូវទទួលការតាមពិនិត្យមើល ពីគ្រូESOL ក្នុងកម្លុងពីរឆ្នាំ។**